# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ: ៥៤ សរន**

## សេចក្តីសំរេច

### ស្តីពី

### ការបង្កើតគណៈកម្មការទាក់ទងជាមួយសមភាគីថៃ និងដោះស្រាយការងារពាក់ព័ន្ធនឹងការអនុវត្តគំរោងផ្លូវលេខ ៤៨

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ១១៩៨ / ៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- យោងតាមតំរូវការចាំបាច់របស់រាជរដ្ឋាភិបាល

### សំរេច

**ប្រការ១ :** បង្កើតគណៈកម្មការទាក់ទងជាមួយសមភាគីថៃ និងដោះស្រាយការងារពាក់ព័ន្ធនឹងការអនុវត្តគំរោងផ្លូវលេខ ៤៨ ដែលមានសមាសភាពដូចខាងក្រោម:

| | | | |
|---|---|---|---|
| ១- ឯកឧត្តម | **ត្រាំ អ៊ីវតឹក** | រដ្ឋលេខាធិការ ក្រសួងសាធារណការ និងដឹកជញ្ជូន | ប្រធាន |
| ២- ឯកឧត្តម | **អ៊ុក ចាន់** | អនុរដ្ឋលេខាធិការ ក្រសួងសាធារណការ និងដឹកជញ្ជូន | អនុប្រធាន |
| ៣- ឯកឧត្តម | **ញាណ ឡេង** | អនុរដ្ឋលេខាធិការ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| ៤- ឯកឧត្តម | **យុទ្ធ ភូថង** | អភិបាលខេត្តកោះកុង | សមាជិក |
| ៥- ឯកឧត្តម | **វង្សី វិស្សុត** | អគ្គលេខាធិការរង ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| ៦- លោក | **ចាន់ សុធី** | ប្រធាននាយកដ្ឋានវិនិយោគនិងសហប្រតិបត្តិការ ស.ហ.វ. | សមាជិក |
| ៧- លោក | **លឹម ស៊ីដេនីន** | ប្រធាននាយកដ្ឋានផ្លូវថ្នល់ ក្រសួងសាធារណការនិងដឹកជញ្ជូន | សមាជិក |
| ៨- លោក | **ឃុយ ហៀង** | អនុប្រធាននាយកដ្ឋានគមនាគមន៍និងប្រៃសណីយ៍ គ.រ.ម | សមាជិក |

**ប្រការ២ :** គណៈកម្មការមានភារកិច្ចធ្វើទំនាក់ទំនងជាមួយសមភាគីថៃ និងដោះស្រាយរាល់ការងារ ដែលពាក់ព័ន្ធនឹងការអនុវត្តគំរោងសាងសង់ផ្លូវលេខ ៤៨ ។

**ប្រការ៣ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដែលមានចែងក្នុងប្រការមួយ ត្រូវអនុវត្តសេចក្តីសំរេចនេះឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

*រាជធានីភ្នំពេញ ថ្ងៃទី ០៨ ខែ កក្កដា ឆ្នាំ ២០០៣*

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចចែងក្នុងប្រការ ៣
- ឯកសារ-កាលប្បវត្តិ